ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៥ របស់ធនាគារជាតិនៃកម្ពុជា

រាជធានីភ្នំពេញ ថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៥

សូមគោរព :

- លោក Hervé DALLERAC ជំនាញការទូទៅប្រចាំធនាគារជាតិនៃកម្ពុជា
- លោក Robert Beerens ជំនាញការប្រចាំធនាគារជាតិនៃកម្ពុជា
- លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអតិបរមា ដោយបានចូលរួមក្នុងសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១៥ របស់យើងនាពេលនេះ ។ ជារៀងរាល់ឆ្នាំ យើងតែងតែប្រារព្ធពិធីនេះឡើង ដើម្បីផ្សព្វផ្សាយនិងអបអរសាទរសមិទ្ធផលការងាររបស់ធនាគារជាតិនៃកម្ពុជាយើង និងផ្តល់ឱកាសដល់មន្ត្រីបុគ្គលិកទាំងនៅស្នាក់ការកណ្តាលនិងសាខារាជធានី-ខេត្ត បានជួបប្រាស្រ័យទាក់ទង និងផ្លាស់ប្តូរបទពិសោធន៍ការងារគ្នា សំដៅពង្រឹងប្រសិទ្ធភាពការងារនិងរួមចំណែកអនុវត្តមុខងារភារកិច្ចរៀងៗខ្លួន ឱ្យសម្រេចបានជោគជ័យថ្មីៗបន្ថែមទៀត ។

ទន្ទឹមនឹងនេះ ខ្ញុំសូមថ្លែងកោតសរសើរចំពោះមន្ត្រីបុគ្គលិកគ្រប់ថ្នាក់ ដែលបានខិតខំប្រឹងប្រែងបំពេញមុខងារភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងសម្រេចបានសមិទ្ធផលជូនធនាគារជាតិនៃកម្ពុជា ជាពិសេសបានរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារកាន់តែឱ្យរីកចម្រើន និងមានលក្ខណៈសមាហរណជាមួយប្រទេសក្នុងតំបន់និងពិភពលោកស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ។



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

- គណៈអធិបតី

- **លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ឆ្លៀតក្នុងឱកាសនេះ មុននឹងជម្រាបជូនពីសមិទ្ធផលការងាររបស់ធនាគារជាតិនៃកម្ពុជាក្នុងឆមាសទី១ ឆ្នាំ២០១៥នេះ ខ្ញុំសូមជម្រាបជូនពីសារៈសំខាន់និងការវិវត្តប្រែប្រួលនៃតួនាទីធនាគារកណ្តាលនៅលើពិភពលោកបច្ចុប្បន្នថា តាមរយៈបទពិសោធន៍ដែលបានរៀនពីវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធំៗ ដូចជា មហាវិបត្តិសេដ្ឋកិច្ចឆ្នាំ១៩២៩ វិបត្តិហិរញ្ញវត្ថុអាស៊ីឆ្នាំ១៩៩៧ និងវិបត្តិហិរញ្ញវត្ថុឆ្នាំ២០០៨ កន្លងមក បានធ្វើឱ្យប៉ះពាល់ដល់ជំនឿទុកចិត្តវិនិយោគិននិងអ្នកប្រើប្រាស់ បានធ្វើឱ្យប្រែប្រួលនិម្មាបនកម្មនិងអភិក្រមហិរញ្ញវត្ថុអន្តរជាតិ និងការប្រែប្រួលនៃតួនាទីធនាគារកណ្តាលក្នុងតំបន់និងពិភពលោកផងដែរ ដែលកាលពីមុនផ្តោតទៅលើការដឹកនាំគោលនយោបាយរូបិយវត្ថុដើម្បីរក្សាស្ថិរភាពថ្លៃ ហើយបច្ចុប្បន្ននេះកំពុងផ្តោតទៅលើស្ថិរភាពហិរញ្ញវត្ថុបន្ថែមទៀត ។ ការប្រែប្រួលថ្មីនេះក៏ជះឥទ្ធិពលដោយប្រយោលមកលើកម្ពុជាផងដែរ ដែលតម្រូវឱ្យអាជ្ញាធរទាំងអស់ ជាពិសេស ធនាគារជាតិនៃកម្ពុជាត្រូវពិចារណារៀបចំកសាងសមត្ថភាព និងក្របខ័ណ្ឌយន្តការការងារ ដើម្បីសម្របខ្លួនទៅតាមនិន្នាការថ្មីនេះដែរ ។

ចំពោះ**សភាពការណ៍ទូទៅនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងសេដ្ឋកិច្ចកម្ពុជា** នៅឆមាសទី១ ឆ្នាំ២០១៥ ខ្ញុំសូមជម្រាបដោយសង្ខេបថា ៖

កំណើនសេដ្ឋកិច្ចសកលបន្តងើបឡើងក្នុងល្បឿនយឺត ដោយសារកំណើនសេដ្ឋកិច្ចប្រទេសធំៗមួយចំនួន ជាពិសេស សហរដ្ឋអាមេរិកនិងចិន បានបន្ថយល្បឿន ។ កំណើនសេដ្ឋកិច្ចសហរដ្ឋអាមេរិកបានថយចុះបន្តិច បណ្តាលមកពីភាពទន់ខ្សោយនៃការប្រើប្រាស់ក្នុងស្រុកនៅរដូវរងា ការថយចុះនៃការវិនិយោគលើវិស័យថាមពល និងការឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិក ដែលបានធ្វើឱ្យប៉ះពាល់ដល់ការនាំចេញ ។ ចំណែកឯ សេដ្ឋកិច្ចតំបន់អឺរ៉ូមានភាពប្រសើរជាងមុនបន្តិច ដែលគាំទ្រដោយកំណើននៃការប្រើប្រាស់ឯកជននិងការនាំចេញដោយសារការធ្លាក់ចុះនៃថ្លៃប្រេងនិងប្រាក់អឺរ៉ូ ។ ដោយឡែក កំណើនសេដ្ឋកិច្ចចិនបានបន្តថយល្បឿនដល់កម្រិតទាបបំផុតក្នុងរយៈពេល ៦ឆ្នាំចុងក្រោយនេះ ដោយសារការថយចុះនៃវិស័យផលិតកម្មនិងការវិនិយោគលើអចលនទ្រព្យ ។ ទន្ទឹមនេះ កំណើនសេដ្ឋកិច្ចប្រទេសនៅតំបន់អាស៊ាន នៅតែនៅរក្សាភាពរឹងមាំដែលគាំទ្រដោយតម្រូវការក្នុងស្រុក ។

ចំពោះសេដ្ឋកិច្ចកម្ពុជាវិញ កំណើនសេដ្ឋកិច្ចបានបន្តរីកចម្រើនរឹងមាំ ដែលគាំទ្រដោយការបន្តងើបឡើងនៃសេដ្ឋកិច្ចសកល រួមនឹងការរក្សាបានស្ថិរភាពនយោបាយ សុខសន្តិភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ លទ្ធផលនៃកម្មវិធីកំណែទម្រង់ និងការអនុវត្តនូវគោលនយោបាយសេដ្ឋកិច្ចចម្បងៗរបស់រាជរដ្ឋាភិបាលប្រកបដោយជោគជ័យ ។ ជាក់ស្តែង

កំណើនសេដ្ឋកិច្ចនៅឆ្នាំ២០១៥ នេះ ត្រូវបានរំពឹងថានឹងកើនឡើងក្នុងអត្រា ៦,៩% ដែលជាចម្បងជំរុញដោយវិស័យកាត់ដេរសម្លៀកបំពាក់ សំណង់និងអចលនទ្រព្យ ខណៈដែលវិស័យទេសចរណ៍និងកសិកម្មមានកំណើនយឺតជាងឆ្នាំមុន ។

ចំណែកឯ **លទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាសម្រេចបាន** ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០ របស់រាជរដ្ឋាភិបាល មានដូចតទៅ ៖

**១/- វិស័យរូបិយវត្ថុ** : នៅក្នុងឆមាសទី១ នេះ តម្លៃប្រាក់រៀលបន្តមានស្ថិរភាពល្អប្រសើរដោយប្រែប្រួលក្នុងរង្វង់ ៤.០៥០ រៀលក្នុងមួយដុល្លារអាមេរិក ។ ស្ថិរភាពនេះទទួលបានតាមរយៈការបន្តអនុវត្តរបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រង ដោយធ្វើអន្តរាគមន៍តាមការចាំបាច់ ជាពិសេស ដើម្បីឆ្លើយតបនឹងកំណើនតម្រូវការប្រាក់រៀល ដែលបានកើនឡើងឥតឈប់ឈរ ។ ចំណែកអតិផរណារួមឆ្នាំលើឆ្នាំ នាដំណាច់ឆមាសនេះ មានកម្រិតទាបប្រមាណតែ ១% ប៉ុណ្ណោះ ។ មកទល់បច្ចុប្បន្ន យើងបានគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុ ប្រកបដោយភាពប្រុងប្រយ័ត្ន ក្នុងកម្រិតសមស្របទៅនឹងការរីកចម្រើននៃសេដ្ឋកិច្ចជាតិ តាមរយៈការផ្គត់ផ្គង់បរិមាណប្រាក់រៀលគ្រប់គ្រាន់តាមតម្រូវការទីផ្សារ និងការកំណត់អត្រាប្រាក់បម្រុងកាតព្វកិច្ចក្នុងកម្រិតដែលអាចរក្សាបរិមាណឥណទាននៅលើទីផ្សារ បានសមស្រប ។ ធនាគារជាតិនៃកម្ពុជាបានគរពូនទុនបម្រុងអន្តរជាតិជាលំដាប់ តាមរយៈការគ្រប់គ្រងយ៉ាងប្រុងប្រយ័ត្នបំផុត និងបានអភិវឌ្ឍក្របខ័ណ្ឌតាមដានវិភាគ និងព្យាករស្ថានភាពសន្ទនីយភាពនៅក្នុងសេដ្ឋកិច្ចប្រចាំថ្ងៃ សំដៅរក្សាកម្រិតសន្ទនីយភាពឱ្យបានគ្រប់គ្រាន់តាមតម្រូវការ ។

**២/- វិស័យធនាគារនិងហិរញ្ញវត្ថុ** : វិស័យនេះបន្តអភិវឌ្ឍរីកចម្រើនគួរឱ្យកត់សម្គាល់ទាំងវិសាលភាព និងទំហំប្រតិបត្តិការ ហើយបានដើរតួនាទីកាន់តែសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ ចំពោះផ្នែកវិសាលភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបន្តពង្រីកបណ្តាញប្រតិបត្តិការ តាមរយៈការបើកសាខានៅតាមរាជធានី-ខេត្ត ។ ចំនួនសាខាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានកើនឡើងជាង ៥ ដង ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ ។ ម៉ាស៊ីន ATM ដែលត្រូវបានបំពាក់ចាប់តាំងឆ្នាំ២០០៥ មក បានកើនឡើងរហូតដល់ជាង ១០០០ គ្រឿង នៅទូទាំងប្រទេស ។ សេវាហិរញ្ញវត្ថុត្រូវបានអភិវឌ្ឍជាបន្តបន្ទាប់ស្របតាមតម្រូវការទីផ្សារ ដើម្បីធ្វើឱ្យអតិថិជនមានលទ្ធភាពប្រើប្រាស់សេវាហិរញ្ញវត្ថុកាន់តែច្រើន ។ ចំពោះទំហំប្រតិបត្តិការវិញ ទាំងប្រាក់បញ្ញើ និងឥណទានរបស់ប្រព័ន្ធធនាគារ បានកើនឡើងយ៉ាងឆាប់រហ័ស ។ បច្ចុប្បន្ន អនុបាតប្រាក់បញ្ញើធៀបនឹងផ.ស.ស បានកើនឡើងដល់ ៥៤% អនុបាតឥណទានធៀបនឹងផ.ស.ស កើនដល់ ៥៥% ធៀបនឹង ១៥% និង ៩% នៅឆ្នាំ២០០៥ ។ ចំណែកឯ ឥណទានមិនដំណើរការ (NPL) មានកម្រិតទាបក្រោម ២,៧% និង ០,៧% ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលបង្ហាញពីគុណភាពល្អនៃសម្ពាធឥណទានរបស់វិស័យធនាគារ ។

ទន្ទឹមនេះ កម្រិតបរិយាប័ន្នហិរញ្ញវត្ថុដែលឆ្លុះបញ្ចាំងតាមរយៈសមាមាត្រចំនួនប្រជាជនប្រើប្រាស់សេវាហិរញ្ញវត្ថុ ធៀបនឹងចំនួនប្រជាជនពេញវ័យសរុប បានកើនឡើងយ៉ាងឆាប់រហ័សក្នុងរយៈពេលមួយទសវត្សនេះដែរ ។ គិតត្រឹមឆមាសទី១ ឆ្នាំ២០១៥ នេះ បរិយាប័ន្នហិរញ្ញវត្ថុ បានកើនឡើងដល់ ៥៦% បើធៀបនឹង ៧% នៅឆ្នាំ២០០៥ ។

ដើម្បីរក្សាបាននិរន្តរភាពនៃការអភិវឌ្ឍប្រព័ន្ធធនាគារ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បានលើកកម្ពស់ជាប្រចាំនូវសមត្ថភាពនិងពង្រឹងវិធីសាស្ត្រត្រួតពិនិត្យ ក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ និងការវិភាគពីហានិភ័យសំខាន់ៗ ក្នុងកម្រិតមីក្រូនិងម៉ាក្រូ ។ ក្នុងកម្រិតមីក្រូ ធនាគារជាតិនៃកម្ពុជាបានបន្តលើកកម្ពស់ការត្រួតពិនិត្យលើឯកសារនិងដល់ទីកន្លែង ដោយបានពង្រឹងការអនុវត្តវិធីសាស្ត្រត្រួតពិនិត្យផ្អែកលើបទប្បញ្ញត្តិ និងវិធីសាស្ត្រត្រួតពិនិត្យផ្អែកលើហានិភ័យនិងទស្សនៈអនាគត ព្រមទាំងបានពង្រឹងវិធានការកែតម្រូវបន្ទាន់ ដើម្បីឆ្លើយតបឱ្យបានទាន់ពេលវេលានឹងហានិភ័យនានាដែលអាចកើតឡើង សំដៅរក្សាសុខភាពគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឱ្យបានរឹងមាំ ។ ក្នុងកម្រិតម៉ាក្រូ ធនាគារជាតិនៃកម្ពុជាបានតាមដានហានិភ័យហិរញ្ញវត្ថុនិងបម្រែបម្រួលនៃបរិស្ថានម៉ាក្រូសេដ្ឋកិច្ច ដែលអាចមានឥទ្ធិពលមកលើវិស័យធនាគារនិងហិរញ្ញវត្ថុទាំងមូល ។ ផ្អែកលើការតាមដានទាំងនេះ វិធានការម៉ាក្រូប្រុងប្រយ័ត្នចាំបាច់មួយចំនួន ត្រូវបានដាក់ចេញដើម្បីទប់ស្កាត់រាល់ហានិភ័យសក្តានុពលនានា សំដៅរក្សាស្ថិរភាពហិរញ្ញវត្ថុ ។

លើសពីនេះ ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុត្រូវបាននិងកំពុងអភិវឌ្ឍជាបន្តបន្ទាប់ ដើម្បីគាំទ្រការរីកចម្រើននៃវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចជា ការពង្រឹងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ព្រមទាំងការអភិវឌ្ឍប្រព័ន្ធទូទាត់វាយអេឡិចត្រូនិក ដើម្បីឱ្យការទូទាត់កាន់តែមានប្រសិទ្ធនិងសុវត្ថិភាព ។

៣/- **ការអភិវឌ្ឍប្រព័ន្ធផាត់ទាត់ជាតិ** : នៅឆមាសនេះ ធនាគារជាតិនៃកម្ពុជាបានរៀបចំប្រព័ន្ធទូទាត់វាយភ្លាមៗ (ប្រព័ន្ធ FAST) ដើម្បីអនុញ្ញាតឱ្យអតិថិជនទទួលបានមូលនិធិភ្លាមៗ និងបានរួមបញ្ចូលគ្នានូវប្រតិបត្តិការទូទាត់អន្តរធនាគារផ្សេងៗ ដើម្បីកាត់បន្ថយចរាចរណ៍សាច់ប្រាក់ និងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ។ យើងក៏បានពង្រឹងច្បាប់និងបទប្បញ្ញត្តិចាំបាច់នានា ដើម្បីគ្រប់គ្រងដំណើរការនៃប្រតិបត្តិការទូទាត់ឱ្យស្របតាមការវិវត្តនៃវិស័យហិរញ្ញវត្ថុបច្ចុប្បន្នផងដែរ ដោយបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធទូទាត់ និងសេចក្តីព្រាងប្រកាសមួយចំនួនទៀតទាក់ទងនឹង ១/. តម្លាភាពនិងការផ្សព្វផ្សាយសេវាទូទាត់សងប្រាក់ពាណិជ្ជកម្មឆ្លងប្រទេស ២/. ការការពារអតិថិជនសម្រាប់ប្រតិបត្តិការទូទាត់ជាអេឡិចត្រូនិក និង ៣/. កិច្ចព្រមព្រៀងប្រើសេវាផ្ទេរប្រាក់ Online ។

**៤/- ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម**

ស្របពេលដែលវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបន្តរីកចម្រើនយ៉ាងឆាប់រហ័ស ការទប់ស្កាត់និងលុបបំបាត់សកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម នៅក្នុងប្រព័ន្ធធនាគារទាំងមូលត្រូវបានបន្តពង្រឹងជាប្រចាំ ។ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានពង្រឹងសមត្ថភាពបទប្បញ្ញត្តិ កិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ទាំងក្នុងស្រុកនិងអន្តរជាតិ និងបានដាក់ចេញនូវវិធានការចាំបាច់នានា សំដៅគ្រប់គ្រងនិងទប់ស្កាត់រាល់ប្រតិបត្តិការសង្ស័យឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ ។ ជាលទ្ធផល កម្ពុជាត្រូវបានក្រុមការងារហិរញ្ញវត្ថុ FATF បញ្ចូលជាសមាជិកនៃក្រុម Egmont ។

**៥/- ការពង្រឹងអភិបាលកិច្ចល្អ** : ក្នុងការពង្រឹងអភិបាលកិច្ចល្អ និងលើកកម្ពស់ការអនុវត្តការងារឱ្យកាន់តែមានប្រសិទ្ធភាព យើងបានបន្តធ្វើសវនកម្មផ្ទៃក្នុង ដោយផ្តោតលើការប្រតិបត្តិតាមបទប្បញ្ញត្តិ នីតិវិធីការងារ និងភាពគ្រប់គ្រាន់នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជាបានចុះធ្វើសវនកម្មនៅនាយកដ្ឋាន និងអង្គភាពក្រោមឱវាទនៅរាជធានី-ខេត្ត ទៅលើប្រតិបត្តិការធនាគារ ។ ចំពោះការងារអធិការកិច្ចវិញ យើងបានចុះត្រួតពិនិត្យនៅសាខាធនាគារជាតិនៃកម្ពុជា ដោយបានផ្តោតជាសំខាន់ទៅលើការធានាសុវត្ថិភាពឃ្លាំងប្រាក់ ការងារគ្រប់គ្រងសាច់ប្រាក់ និងការអនុវត្តរាល់សេចក្តីណែនាំរបស់នាយកដ្ឋានជំនាញ ព្រមទាំងបានពង្រឹងគុណវុឌ្ឍិ វិន័យការងាររបស់មន្ត្រីបុគ្គលិក និងប្រសិទ្ធភាពការងារនៅតាមសាខាឱ្យកាន់តែប្រសើរ ។

**៦/- ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស** : ធនធានមនុស្ស ត្រូវបានគ្រប់គ្រងពង្រឹង និងអភិវឌ្ឍជាបន្តបន្ទាប់ ស្របតាមតម្រូវការការងារ គោលការណ៍នៃស្ថិរភាព និងប្រសិទ្ធភាពការងារនៅធនាគារជាតិនៃកម្ពុជា ព្រមទាំងការវិវត្តនិម្មាបនកម្មហិរញ្ញវត្ថុជាតិនិងតំបន់ ។ យើងបានផ្តល់ការបណ្តុះបណ្តាលទាំងក្នុងប្រទេស និងបានបញ្ជូនមន្ត្រីបុគ្គលិករបស់យើងទៅចូលរួមវគ្គបណ្តុះបណ្តាលនានាក្រៅប្រទេស ទាំងរយៈកាលខ្លី និងវែង ។ បច្ចុប្បន្ន ការបណ្តុះបណ្តាលធនធានមនុស្សនៅធនាគារជាតិនៃកម្ពុជា ត្រូវបានលើកកម្ពស់ទាំងការយល់ដឹងផ្នែកជំនាញ និងឯកទេសកម្មបច្ចេកទេសតាមផ្នែកនីមួយៗនៃប្រតិបត្តិការធនាគារកណ្តាល ដើម្បីឆ្លើយតបទៅនឹងតម្រូវការការងាររបស់ធនាគារជាតិនៃកម្ពុជា និងការប្រែប្រួលនៃស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងតំបន់និងអន្តរជាតិ ។

**៧/- ការពង្រឹងប្រតិបត្តិការសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត** : ដើម្បីពង្រឹងសេវាធនាគារកណ្តាលឱ្យកាន់តែមានប្រសិទ្ធភាព ជាពិសេសការសម្រួលចរាចរណ៍សាច់ប្រាក់នៅទូទាំងប្រទេស យើងកំពុងជួសជុលកែលម្អ និងបំពាក់ប្រព័ន្ធសុវត្ថិភាពអាគារសាខា

ធនាគារជាតិនៃកម្ពុជា ។ ទន្ទឹមនោះ យើងក៏បានបន្តពង្រឹងកិច្ចសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ។

៨/- **កិច្ចសហប្រតិបត្តិការអន្តរជាតិ** : ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងនិងពង្រីកជាប់ជាប្រចាំនូវ កិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគីជាមួយធនាគារកណ្តាល ស្ថាប័នហិរញ្ញវត្ថុ និងវិទ្យាស្ថានបណ្តុះបណ្តាលទាំងក្នុងតំបន់និងអន្តរជាតិ ដើម្បីផ្លាស់ប្តូរព័ត៌មាននិងបទពិសោធន៍ ព្រមទាំងបង្កើនកិច្ចសហប្រតិបត្តិការទៅលើវិស័យជំនាញនានា ។ តាមរយៈកិច្ចសហប្រតិបត្តិការនេះ ធនាគារជាតិនៃកម្ពុជាក៏ទទួលបាននូវជំនួយបច្ចេកទេស និងការបណ្តុះបណ្តាលរយៈពេលខ្លីនិងវែង ដើម្បីអភិវឌ្ឍសមត្ថភាពមន្ត្រីធនាគារជាតិនៃកម្ពុជាសម្រាប់រួមចំណែកកាន់តែសកម្មនិងមានប្រសិទ្ធភាពក្នុងការពង្រឹងប្រព័ន្ធធនាគារ ឱ្យមានលក្ខណៈសមាហរណកម្ម និងប្រកួតប្រជែងខ្ពស់ក្នុងតំបន់ ។

លើសពីនេះ ធនាគារជាតិនៃកម្ពុជាបានគាំទ្រនិងរួមចំណែកក្នុងគំនិតផ្តួចផ្តើមនានាដើម្បីជំរុញសមាហរណកម្មហិរញ្ញវត្ថុអាស៊ាននិងអាស៊ាន+៣ សំដៅបង្កើតសហគមន៍អាស៊ាន (AEC) នៅចុងឆ្នាំ២០១៥ នេះ និងពង្រីកបណ្តាញសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុតំបន់ ។

យើងក៏មានមោទនភាពជាខ្លាំង ដោយសារតែការរីកចម្រើនវិស័យធនាគារ ត្រូវបានទទួលស្គាល់នៅលើឆាកអន្តរជាតិ ។ មន្ត្រីធនាគារជាតិនៃកម្ពុជាយើងត្រូវបានអញ្ជើញឱ្យធ្វើជាវាគ្មិនដើម្បីចែករំលែកបទពិសោធន៍ក្នុងការអភិវឌ្ឍវិស័យធនាគារ ជាពិសេស ក្នុងការត្រួតពិនិត្យប្រព័ន្ធធនាគារដល់ប្រទេសមួយចំនួនក្នុងតំបន់ ដូចជា ប្រទេសឡាវ មីយ៉ាន់ម៉ា បង់ក្លាដែស ជាដើម ។

**- គណៈអធិបតី**

**- លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

សរុបមក សមិទ្ធផលទាំងឡាយដែលយើងសម្រេចបានសព្វថ្ងៃនេះ បានមកពីការខិតខំប្រឹងប្រែងបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់របស់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា និងការចូលរួមសហការពីក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ។ ដើម្បីយល់ឱ្យកាន់តែច្បាស់ និងជ្រាបកាន់តែលម្អិតថែមទៀតនៃសមិទ្ធផលរបស់យើង សូមអង្គសន្និបាតមេត្តាត្រងត្រាប់ស្តាប់បទឧទ្ទេសនាមរបស់ថ្នាក់ដឹកនាំរបស់យើង ដែលនឹងរាយការណ៍ជូនអង្គសន្និបាតក្នុងពេលបន្តិចទៀតនេះ ដើម្បីយកទៅអនុវត្តការងាររបស់ខ្លួនឱ្យបានជោគជ័យនិងមានប្រសិទ្ធភាពថែមទៀត ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសមាជិកក្រុមប្រឹក្សាភិបាល និងមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទាំងអស់ ដែលបានខិតខំប្រឹងប្រែងរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារនៅកម្ពុជា ឱ្យរីកចម្រើននិងសម្រេចបានសមិទ្ធផលជាទីមោទនៈ ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែងរបស់រាជរដ្ឋាភិបាល ដើម្បីគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព សមភាព និងបរិយាប័ន្ន ។ ខ្ញុំនៅតែមានជំនឿជឿជាក់ថា លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា នៅតែបន្តស្មារតីសាមគ្គីគ្នាជាប្រពៃណីនេះតទៅទៀត ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់ លោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញា ដែលមានវត្តមាននៅក្នុងអង្គសន្និបាតនេះ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។ ខ្ញុំសូមឱ្យអង្គសន្និបាតរបស់យើងមានដំណើរការប្រកបដោយជោគជ័យ ។

**ខ្ញុំសូមប្រកាសបើកអង្គសន្និបាតជាផ្លូវការចាប់ពីពេលនេះតទៅ ។**

**សូមអរគុណ!**